ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៣២០ សហវ.ប្រក.[illegible]

# ប្រកាស
# ស្ដីពី
# ការណែនាំអនុវត្ត
# អនុក្រឹត្យស្ដីពីការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ ស្ដីពីការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៤ ស្ដីពីការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ
- បានឃើញប្រកាសលេខ ០០៩ សហវ.ប្រក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ ស្ដីពីការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស

- បានឃើញប្រកាសលេខ ៧០១ សហវ.ប្រក ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០ ស្តីពីការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងកំណត់អំពីវិធាននិងនីតិវិធីនៃការលើកទឹកចិត្តផ្នែកពន្ធដារ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ចំពោះសហគ្រាសស្ថិតក្នុងវិស័យអាទិភាព។

**ប្រការ២.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះសហគ្រាសធុនមីក្រូ សហគ្រាសធុនតូច និងសហគ្រាសធុនមធ្យម ដែលចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្ត ដើម្បីប្រកបអាជីវកម្មណាមួយក្នុងវិស័យអាទិភាព ដូចខាងក្រោម៖

- លក់ដុំ លក់រាយ និងជួសជុល
- សេវាកម្មស្នាក់នៅនិងអាហារ
- សិប្បកម្ម និង
- សហគមន៍កសិកម្ម។

**ប្រការ៣.-**

សម្រាប់គោលដៅនៃប្រកាសនេះ៖

១- សហគ្រាសធុនមីក្រូ គឺជាសហគ្រាសឯកបុគ្គល ឬសហគ្រាសសហកម្មសិទ្ធិ ដែលមានផលរបរប្រចាំឆ្នាំក្រោម ២៥០ លានរៀល ឬទ្រព្យសកម្មក្រោម ២០០ លានរៀល ឬមានកម្មករឬនិយោជិតចាប់ពី ១នាក់ ដល់ ៤នាក់។ សហគ្រាសធុនមីក្រូ ត្រូវចាត់ទុកជាអ្នកជាប់ពន្ធមានផលរបរប្រចាំឆ្នាំតិចជាង ២៥០ លានរៀល។

២- សហគ្រាសធុនតូច គឺជាសហគ្រាសឯកបុគ្គល ឬសហគ្រាសសហកម្មសិទ្ធិ ដែល៖

ក- មានផលរបរប្រចាំឆ្នាំចាប់ពី ២៥០ លានរៀល ដល់ ១ ០០០ លានរៀល ឬមានទ្រព្យសកម្មអាជីវកម្មប្រចាំឆ្នាំចាប់ពី ២០០ លានរៀល ដល់ ១ ០០០ លានរៀល សម្រាប់វិស័យកសិកម្ម (សហគមន៍កសិកម្ម), សេវាកម្ម (សេវាកម្មស្នាក់នៅនិងអាហារ) និងពាណិជ្ជកម្ម (លក់ដុំ លក់រាយ និងជួសជុល) ឬ

ខ- មានផលរបរប្រចាំឆ្នាំចាប់ពី ២៥០ លានរៀល ដល់ ១ ៦០០ លានរៀល ឬមានទ្រព្យសកម្មអាជីវកម្មប្រចាំឆ្នាំចាប់ពី ២០០ លានរៀល ដល់ ២ ០០០ លានរៀល សម្រាប់វិស័យឧស្សាហកម្ម (សិប្បកម្ម) ឬ

គ- មានផលរបរក្នុងរយៈពេល បីខែ ជាប់គ្នាណាមួយ ដែលបញ្ចប់ក្នុងឆ្នាំប្រតិទិនចរន្ត ចាប់ពី ៦០ លានរៀល ឡើងទៅ ឬ

ឃ- រំពឹងថាមានផលរបរក្នុងរយៈពេល បីខែ ជាប់គ្នាខាងមុខ ចាប់ពី ៦០ លានរៀល ឡើងទៅ ឬ

ង- ចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬស្នង់ថ្លៃ ក្នុងការផ្គត់ផ្គង់ទំនិញឬសេវាដោយប្រើប្រាស់ថវិការដ្ឋ រួមទាំងភាស៊ី ឬ

ច- មានកម្មករឬនិយោជិតចាប់ពី ៥នាក់ ដល់ ៤៩នាក់។

សហគ្រាសធុនតូច ត្រូវបានចាត់ទុកជាអ្នកជាប់ពន្ធតូច។

៣- សហគ្រាសធុនមធ្យម គឺជាបុគ្គលដែលស្ថិតនៅក្នុងលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌខាងក្រោម៖

ក- មានផលរបរប្រចាំឆ្នាំលើសពី ១ ០០០ លានរៀល ដល់ ៤ ០០០ លានរៀល ឬមានទ្រព្យសកម្មអាជីវកម្មប្រចាំឆ្នាំលើសពី ១ ០០០ លានរៀល ដល់ ២ ០០០ លានរៀល សម្រាប់វិស័យកសិកម្ម (សហគមន៍កសិកម្ម)

ខ- មានផលរបរប្រចាំឆ្នាំលើសពី ១ ០០០ លានរៀល ដល់ ៦ ០០០ លានរៀល ឬមានទ្រព្យសកម្មអាជីវកម្មប្រចាំឆ្នាំលើសពី ១ ០០០ លានរៀល ដល់ ២ ០០០ លានរៀល សម្រាប់វិស័យសេវាកម្ម (សេវាកម្មស្នាក់នៅនិងអាហារ) និងពាណិជ្ជកម្ម (លក់ដុំ លក់រាយ និងជួសជុល) ឬ

គ- មានផលរបរប្រចាំឆ្នាំលើសពី ១ ៦០០ លានរៀល ដល់ ៨ ០០០ លានរៀល ឬមានទ្រព្យសកម្មអាជីវកម្មប្រចាំឆ្នាំលើសពី ២ ០០០ លានរៀល ដល់ ៤ ០០០ លានរៀល សម្រាប់វិស័យឧស្សាហកម្ម (សិប្បកម្ម) ឬ

ឃ- ជាសហគ្រាសដែលបានចុះបញ្ជីជានីតិបុគ្គល ការិយាល័យតំណាង ឬ

ង- មានកម្មករឬនិយោជិតចាប់ពី ៥០នាក់ ដល់ ១៩៩នាក់។

សហគ្រាសធុនមធ្យម ត្រូវបានចាត់ទុកជាអ្នកជាប់ពន្ធមធ្យម។

៤- ការចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្ត សំដៅដល់ការចុះបញ្ជីពន្ធដាររបស់សហគ្រាសតាមរយៈគេហទំព័រចុះបញ្ជីអាជីវកម្ម https://www.registrationservices.gov.kh (CamDX) ឬដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ ដែលមិនមែនជាការចុះបញ្ជីដោយឯកតោភាគីរបស់រដ្ឋបាលសារពើពន្ធ។

៥- ផលរបរ សំដៅដល់ តម្លៃនៃការផ្គត់ផ្គង់ទំនិញ ឬសេវាដែលជាសកម្មភាពអាជីវកម្មរបស់អ្នកជាប់ពន្ធ។

៦- ទ្រព្យសកម្ម សំដៅដល់ ទ្រព្យសម្បត្តិនានាដែលត្រូវបានយកទៅប្រើប្រាស់ក្នុងអាជីវកម្មដែលរួមមានទ្រព្យសកម្មរយៈពេលខ្លី និងទ្រព្យសកម្មរយៈពេលវែង។

**ប្រការ៤ ._**

សហគ្រាសធុនមីក្រូ សហគ្រាសធុនតូច និងសហគ្រាសធុនមធ្យម ត្រូវទទួលបានការលើកទឹកចិត្តផ្នែកពន្ធដារដូចខាងក្រោម៖

១- ចំពោះការចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្តក្នុងឆ្នាំ ២០២៣-២០២៨ សម្រាប់សហគ្រាសធុនមីក្រូ ត្រូវបានលើកលែងកម្រៃសេវាចុះបញ្ជីពន្ធដារ កម្រៃសេវាធ្វើបច្ចុប្បន្នភាពព័ត៌មាន និងកម្រៃសេវាបោះពុម្ពបណ្ណសម្គាល់ការចុះបញ្ជី។

២- ចំពោះការចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្តក្នុងឆ្នាំ២០២៣-២០២៨ សម្រាប់សហគ្រាសធុនតូច ទទួលបានការលើកលែងដូចតទៅ៖

- ពិន័យទោសទណ្ឌនិងបំណុលពន្ធ រួមមាន ប្រាក់ពន្ធ ពន្ធបន្ថែម ការប្រាក់ និងការផាកពិន័យជាប្រាក់ពាក់ព័ន្ធផ្ទាល់នឹងអាជីវកម្មរបស់សហគ្រាស ចំពោះការមិនបានបំពេញអនុលោមភាពកន្លងមកមុនការចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្ត
- កម្រៃសេវាចុះបញ្ជីពន្ធដារ កម្រៃសេវាធ្វើបច្ចុប្បន្នភាពព័ត៌មាន និងកម្រៃសេវាបោះពុម្ពបណ្ណសម្គាល់ការចុះបញ្ជី
- ពន្ធប៉ាតង់ នៅពេលចុះបញ្ជីពន្ធដារ
- ពន្ធប៉ាតង់ សម្រាប់រយៈពេល ២ឆ្នាំ ក្រោយការចុះបញ្ជីពន្ធដារបានសម្រេច ក្នុងឆ្នាំ២០២៤ ឬឆ្នាំ២០២៥
- ប្រាក់រំដោះពន្ធលើប្រាក់ចំណូល ពន្ធលើប្រាក់ចំណូល និងពន្ធអប្បបរមា សម្រាប់រយៈពេល ២ឆ្នាំ ក្រោយការចុះបញ្ជីពន្ធដារ ដោយគិតចាប់ពីឆ្នាំទទួលបានការសម្រេចឱ្យចុះបញ្ជីពន្ធដារ និងឆ្នាំជាប់ពន្ធបន្ទាប់។

៣- ចំពោះការចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្តក្នុងឆ្នាំ២០២៤-២០២៥ សម្រាប់សហគ្រាសធុនមធ្យម ទទួលបានការលើកលែងដូចតទៅ៖

- ពិន័យទោសទណ្ឌនិងបំណុលពន្ធ រួមមាន ប្រាក់ពន្ធ ពន្ធបន្ថែម ការប្រាក់ និងការផាកពិន័យជាប្រាក់ពាក់ព័ន្ធផ្ទាល់នឹងអាជីវកម្មរបស់សហគ្រាស ចំពោះការមិនបានបំពេញអនុលោមភាពកន្លងមកមុនការចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្ត
- ពន្ធប៉ាតង់ នៅពេលចុះបញ្ជីពន្ធដារ
- ពន្ធប៉ាតង់ សម្រាប់រយៈពេល ២ឆ្នាំ ក្រោយការចុះបញ្ជីពន្ធដារបានសម្រេច ក្នុងឆ្នាំ២០២៤ ឬឆ្នាំ២០២៥
- ប្រាក់រំដោះពន្ធលើប្រាក់ចំណូល ពន្ធលើប្រាក់ចំណូល និងពន្ធអប្បបរមា សម្រាប់រយៈពេល ២ឆ្នាំ ក្រោយការចុះបញ្ជីពន្ធដារ ដោយគិតចាប់ពីឆ្នាំទទួលបានការសម្រេចឱ្យចុះបញ្ជីពន្ធដារ និងឆ្នាំជាប់ពន្ធបន្ទាប់។

រាល់ការលើកលែងពន្ធ និងកម្រៃសេវាសាធារណៈទាំងឡាយនៅពេលចុះបញ្ជីពន្ធដារ និងក្រោយពេលទទួលបានការសម្រេចឱ្យចុះបញ្ជីពន្ធដារ ដូចមានចែងក្នុងប្រការ៤ នៃប្រកាសនេះ ត្រូវចាត់ទុកជាបន្ទុករបស់រដ្ឋ។

**ប្រការ៥ .-**

សហគ្រាសធុនមីក្រូ សហគ្រាសធុនតូច និងសហគ្រាសធុនមធ្យម ដែលអាចទទួលបានការលើកទឹកចិត្តផ្នែកពន្ធដារ ត្រូវគោរពតាមលក្ខខណ្ឌដូចខាងក្រោម៖

- ចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្តតាមរយៈគេហទំព័រចុះបញ្ជីអាជីវកម្ម https://www.registrationservices.gov.kh (CamDX) ឬដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ ដែលមិនមែនជាការចុះបញ្ជីដោយឯកតោភាគីរបស់រដ្ឋបាលសារពើពន្ធ
- ស្ថិតនៅក្នុងវិស័យអាទិភាព នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដូចមានចែងក្នុងប្រការ២ នៃប្រកាសនេះ។

បែបបទនិងនីតិវិធីនៃការអនុវត្តប្រកាសនេះ ត្រូវកំណត់ដោយសេចក្តីណែនាំរបស់អគ្គនាយកដ្ឋានពន្ធដារ។

**ប្រការ៦ .-**

សហគ្រាសដែលទទួលបានការលើកទឹកចិត្តផ្នែកពន្ធដារនេះ ត្រូវបំពេញកាតព្វកិច្ចដូចខាងក្រោម៖

១- សហគ្រាសធុនមីក្រូ ត្រូវជូនដំណឹងមករដ្ឋបាលសារពើពន្ធអំពី៖

- ផលរបរប្រចាំឆ្នាំ តាមទម្រង់កំណត់ដោយរដ្ឋបាលសារពើពន្ធ ចាប់ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា នៃឆ្នាំបន្ទាប់
- ការផ្លាស់ប្តូរព័ត៌មានផ្សេងៗ ក្នុងអំឡុងពេល ១៥ថ្ងៃ ក្រោយពីការផ្លាស់ប្តូរអាសយដ្ឋាន នាមករណ៍ កម្មវត្ថុអាជីវកម្ម ការផ្ទេរ ការបញ្ឈប់អាជីវកម្ម លេខទូរស័ព្ទ និងសារអេឡិចត្រូនិក។

២- សហគ្រាសធុនតូចនិងមធ្យម ត្រូវ៖

- ជូនដំណឹងមករដ្ឋបាលសារពើពន្ធ ក្នុងអំឡុងពេល ១៥ថ្ងៃ ក្រោយពីការផ្លាស់ប្តូរអាសយដ្ឋានទ្រព្យទ្រង់ទ្រាយ នាមករណ៍ កម្មវត្ថុអាជីវកម្ម ការផ្ទេរនិងការផ្លាស់ប្តូរម្ចាស់ភាគហ៊ុន សមាសភាពអ្នកគ្រប់គ្រងសហគ្រាសឬសាខា ការបញ្ឈប់អាជីវកម្ម អ្នកទទួលបន្ទុកកិច្ចការពន្ធដារ ព័ត៌មានគណនីធនាគារ ព័ត៌មានទំនាក់ទំនង លេខទូរស័ព្ទ និងសារអេឡិចត្រូនិក
- កាន់បញ្ជិកាគណនេយ្យ និងដាក់លិខិតប្រកាសសារពើពន្ធទៅតាមការកំណត់របស់រដ្ឋបាលសារពើពន្ធ ទោះបីជាត្រូវបានលើកលែងប្រាក់រំដោះពន្ធលើប្រាក់ចំណូល ពន្ធលើប្រាក់ចំណូល និងពន្ធអប្បបរមា ដូចមានចែងក្នុងប្រកាសនេះក៏ដោយ
- ដាក់លិខិតប្រកាសនិងបង់ពន្ធអាករដទៃទៀតប្រចាំខែ និងប្រចាំឆ្នាំ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារជាធរមាន។

**ប្រការ៧ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៨ .-**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន ឬអគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១៣កើត ខែ ជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី-ខេត្ត
- ដូចប្រការ៨ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ